<u>ជីវប្រវត្តិអ្នកនិពន្ធ</u>

**ពុទ្ធំ សរណំ គច្ឆាមិ**

*ខ្ញុំព្រះករុណា សូមដល់នូវ*

**ព្រះពុទ្ធ**

*ជាទីពឹងទីរលឹក*

**ធម្មំ សរណំ គច្ឆាមិ**

*ខ្ញុំព្រះករុណា សូមដល់នូវ*

**ព្រះធម៌**

*ជាទីពឹងទីរលឹក*

**សង្ឃំ សរណំ គច្ឆាមិ**

*ខ្ញុំព្រះករុណាសូមដល់នូវ*

**ព្រះសង្ឃ**

*ជាទីពឹងទីរលឹក*



*អាន ត្យាគីម កើតនៅថ្ងៃសុក្រ ១កើតខែជេស្ឋ ឆ្នាំមមី ត្រូវនឹងថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៤២ នៅឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្ដាល ប្រទេសកម្ពុជា ។ ឪពុកឈ្មោះ អាន ស៊ុនហេង ម្ដាយឈ្មោះ អ៊ា គិមអេង របររកចិញ្ចឹមជីវិត លក់ដូរគ្រឿងឧបភោគ បរិភោគ។ កាលនៅកុមារភាព បានរៀនអក្សរខ្មែរ ចេះមើលសាត្រាស្លឹករឹត ដោយនៅវត្ត មង្គលសត្ថាវ៉ន ភូមិព្រៃកតាគង់ ឃុំព្រែកតាសេក ស្រុកមុខកំពូល ខេត្តកណ្ដាល។ ដល់ អាយុ៩ឆ្នាំ មានបង្កើតសាលាបឋមសិក្សា នៅ ឃុំព្រែកលៀប ទើបបានមកសុំចូលរៀន*

នៅថ្នាក់ បរិវិច្ឆនដ្ឋាន (cours préparatoire) ។ ដល់អាយុ ១២ឆ្នាំ ពេលវិស្សមកាល បានបួសជាសាមណេរ នៅវត្ត មង្គលសត្ថារ័នហើយ ចាកសិក្ខា មុនពេលចាប់ផ្តើម ឆ្នាំសិក្សាថ្មី ។ ជាមួយគ្នានោះ បានប្តូរសាលា មករៀននៅសាលាបឋមសិក្សាឫស្សីកែវ សង្កាត់លេខ១ ក្រុងភ្នំពេញ ។ ដល់បានជាប់ សញ្ញាប័ត្រ បឋមសិក្សាហើយ ដោយប្រឡងប្រជែងចូលថ្នាក់ទី៦ នៃវិទ្យាល័យ ស៊ីសុវត្ថិ មិនជាប់ ក៏មករៀន នៅសាលាឯកជនខាងគ្រិស្តសាសនា (école Miche) រហូតដល់ជាប់ សញ្ញាបត្រ័មធ្យមសិក្សា (diplôme de l'enseignement secondaire) ទើបមានច្បាប់សុំចូលរៀននៅថ្នាក់ទី ២ (classe de seconde) នៃវិទ្យាល័យ ស៊ីសុវត្ថិ ដោយមិនចាំបាច់ប្រឡងចូល ។

សូមជំរាបថា កាលខ្ញុំរៀននៅ សាលា Miche លោកគ្រូដែលជាអ្នកបួសក្នុងគ្រិស្តសាសនា នៅឆ្នាំដំបូង គាត់ពន្យល់សាសនា មួយថ្ងៃ មួយម៉ោង ពេញមួយឆ្នាំ។ ដល់ខ្ញុំជាប់ ឌីប៉្លូម ខ្ញុំទៅសុំលាមករៀននៅ វិទ្យាល័យ ស៊ីសុវត្ថិវិញ នោះលោកនាយកសាលា ដែលជាអ្នកបួស ជនជាតិកាណាដា (CANADA) បានហៅខ្ញុំទៅជួប ដើម្បីពន្យល់ខ្ញុំថែមទៀត អំពីសាសនារបស់លោក និងការលះបង់របស់លោក ដើម្បី គ្រិស្តសាសនា ។ បំណង របស់លោក គឺចង់បញ្ចុះ បញ្ចូលខ្ញុំ ឲ្យមកកាន់ គ្រិស្តសាសនាវិញ ។ តែដោយការអប់រំរបស់ខ្ញុំ តាំងពីកុមារមក ព្រមទាំងគ្រួសារ ខាងឪពុកខ្ញុំ សុទ្ធតែជាអ្នកធម៌អាថ៌ នោះបន្ទាប់ពីខំពន្យល់ខ្ញុំអស់មួយព្រឹកធំមក លោកក៏អស់មធ្យោបាយ អស់សង្ឃឹម ព្រោះស្តាយខ្ញុំដោយឃើញខ្ញុំនៅក្នុងថ្នាក់ រៀនមុខវិជ្ជាខ្លះមិនចាញ់កូនយួន ដូចជាគណិតសាស្ត្រជាដើម ថ្វីបើកូនខ្មែរមានតែបីបួននាក់ក៏ដោយក្រៅពីនោះភាគច្រើនគឺកូនយួន[1] ។ ម្យ៉ាងទៀត ក្នុងចំ

[1] អ្នកខ្លះចង់ឲ្យយើងស្រឡាញ់គេ ចង់ឲ្យយើងគោរពគេ តែគេធ្វើបាបយើង គេមានចិត្តមិនត្រង់នឹងយើង តើឲ្យយើងស្រឡាញ់ គោរពម្តេចនឹងកើត ។ ពីព្រោះតាមធម្មតា គេអាចបង្ខំកាយអ្នកដទៃបាន តែបង្ខំចិត្តមិនបានទេ នេះតាមព្រះពុទ្ធសាសនា ពីព្រោះចិត្ត ជាធំ ជាប្រធាន មានឥទ្ធិ

ណោមសាលាឯកជន សាលានោះយកថ្លៃដាំងគេ  ហើយពិបាកនឹងចូលទៀត ។ ចំពោះ កូនខ្មែរ សាលាតម្រូវឲ្យធ្វើការប្រឡងចូលជាមុនសិន ដោយគេទុកកន្លែងសម្រាប់តែ កូនយួន នឹង កូនជនជាតិបរទេស ។

ដល់ខ្ញុំមករៀននៅវិទ្យាល័យស៊ីសុវត្ថិ  ខ្ញុំមានចំណោទខាងអក្សរខ្មែរ  ពីព្រោះខ្ញុំរៀនបាន តិចនៅសាលា Miche តែចំពោះមុខវិជ្ជាផ្សេងៗទៀត ខ្ញុំរៀនទាន់ រហូតដល់ថ្នាក់ទី១(classe de première) ខ្ញុំបានអាហារូបករណ៍ រស់នៅក្នុងសាលាដល់ជាប់ បាក់ឌុប (Bac. 2ème partie)  ផ្នែកគណិតសាស្ត្រ ។ ខ្ញុំចូលចិត្តរៀនគណិតសាស្ត្រតាំងពីក្មេង  នេះដោយសារ ឪពុកខ្ញុំ គាត់មានការអំណត់ ខំពន្យល់ខ្ញុំ ទាល់តែខ្ញុំបានយល់។ ហើយខ្ញុំក៏ចាប់ស្រឡាញ់ គណិតសាស្ត្រ រហូតមក ។ មករៀននៅមហាវិទ្យាល័យ ខ្ញុំយកគណិតសាស្ត្រទៀត។ ខ្ញុំមានបរិញ្ញាប័ត្រផ្នែកគណិតសាស្ត្រ និងចេញពីសាលាគរុកោសល្យជាន់ខ្ពស់ ក្រុងភ្នំ ពេញនៅឆ្នាំ ១៩៦៨ ។ បន្ទាប់មកខ្ញុំធ្វើជាសាស្ត្រាចារ្យផ្នែកគណិតសាស្ត្របង្រៀននៅ ថ្នាក់ទីបញ្ចប់ ផ្នែកគណិតសាស្ត្រ នៃវិទ្យាល័យនានាក្នុងប្រទេស ដូចជា វិទ្យាល័យព្រះ សីហនុ នៅកំពង់ចាម ឬ វិទ្យាល័យស៊ីសុវត្ថិជាដើម ។ បន្ទាប់ពីបានបង្រៀនចំនួន ប្រាំឆ្នាំ

---

ពលខ្លាំងណាស់ ។ បើស្រឡាញ់ហើយ ចិត្តហ៊ានប្តូរស្លាប់រស់ ដើម្បីនឹងជួយគ្នាទៅវិញទៅមក ។ ដូច្នេះមិនពិបាកទេ បើចង់លុបពាក្យយួន ហើយដាក់ពាក្យ វៀតណាមជំនួសវិញ ឬ ក៏លុបពាក្យ សៀម ហើយដាក់ពាក្យថៃជំនួសវិញនោះ  សូមឲ្យអ្នកដឹកនាំប្រទេសទាំងពីរនេះ គោរពបូរណ ភាពទឹកដីខ្មែរ ស្រឡាញ់រាប់អានខ្មែរដោយចិត្តស្មោះត្រង់ មិនកេងប្រវ័ញ្ច  ឬប្រើកម្លាំងអាវុធ មក លើប្រជារាស្ត្រខ្មែរ ដែលសុំតែសេចក្តីសុខសន្តិភាព រស់នៅដោយសម្មាអាជីវៈ ។  អ្នកណាក៏ចង់ បានសេចក្តីសុខ សេចក្តីចំរើនដែរ មិនថាតែ វៀតណាម ថៃ ឬ ខ្មែរ ទេ ។នេះជាច្បាប់ធម្មជាតិ ជាធម្មព្រះពុទ្ធ ហើយប្រទេសយើងទាំង បី  សុទ្ធតែកាន់ធម៌ព្រះពុទ្ធទាំងអស់គ្នា ។

មក ខ្ញុំបានទទួលអាហារូបករណ៍ពីប្រទេសបារាំង មកបន្តវិជ្ជានៅប្រទេសនេះនៅឆ្នាំ ១៩៧៣ ។ ដោយសារគ្រូរបស់ខ្ញុំ លោក តាន់ ប៊ុនសួ (Tan Bun Sor) បានជួយទាក់ទង គ្រូធំរបស់លោក ឈ្មោះ Monsieur Jean LEGRAS (Nancy-France) ដែលលោកគ្រូខ្ញុំបាន ស្គាល់កាលពីពេលលោកធ្វើនិក្ខេបបទ ខ្ញុំក៏បានលោកសាស្ត្រាចារ្យ Jean LEGRAS ជួយនែនាំតមក ។ មកដល់ប្រទេសបារាំង លោក Jean LEGRAS ឲ្យខ្ញុំរៀនខាង ពត៌មានវិជ្ជា (informatique) បន្ទាប់មក លោកឲ្យខ្ញុំនូវ ប្រធានបទ ជានិក្ខេបបទមួយខាងគណិតសាស្ត្រអនុវត្ត (mathématiques appliquées) ដែលត្រូវការចំណេះខាងពត៌មានវិជ្ជាថែមទៀត ដើម្បីនឹងគណនានូវសមីការផ្សេងៗ ។

នៅ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៧៧ ខ្ញុំបានគាំទ្រការស្រាវជ្រាវរបស់ខ្ញុំនៅមុខ គណៈកម្មាធិការមេប្រយោគ ដែលមាន លោក Jean LEGRAS ជាប្រធាន ហើយខ្ញុំក៏ បានជាប់ សញ្ញាប័ត្របណ្ឌិត ផ្នែកពត៌មានវិជ្ជាខាងការសម្រេច (Informatique de la décision) នៅពេលនោះ ដោយនិទ្ទេសកិត្តិយសខ្ពស់បំផុត (avec mention très honorable) ។ ដោយកាលនោះ ស្ថានការណ៍នៅ ប្រទេសយើងកំពុងតែមានការ ច្របូកច្របល់នៅឡើយ អត់មានដំណឹងពីឪពុកម្តាយនិងបងប្អូនខ្ញុំក៏សម្រេចចិត្តរកការងារធ្វើសិនជាបណ្តោះ អាសន្ន ដោយមិនសុខចិត្តសុំចូលជាជនភៀសខ្លួនទេ (réfugié politique) ពីព្រោះខ្ញុំបម្រុង នឹងវិលត្រឡប់ទៅស្រុកវិញ ដើម្បីជួបជុំ កូនខ្ញុំ និងឪពុកម្តាយ បងប្អូន ដែលខ្ញុំឃ្លាតឆ្ងាយ ជាងបីឆ្នាំមកហើយ ។ ដោយគ្មានដំណឹងពីក្មួយខ្ញុំ និងមិត្តភក្តិខ្លះដែលបានចូលទៅក្នុង ស្រុក ខ្ញុំក៏ចេះតែរស់នៅស្រុកគេ តៗទៅរហូតមកដល់សព្វថ្ងៃនេះ (ឆ្នាំ ២០១៧)។ ក្នុងការជួយស្រុកទេស ខ្ញុំមានលទ្ធភាពបានត្រឹម សរសេរ គណិតសាស្ត្រ **ជាភាសាខ្មែរ** ចុះផ្សាយជាសាធារណៈ ជាធម្មទាន បណ្តើរៗ តាមប្រព័ន្ធអាំងតែនែត (lien d’internet) របស់ខ្ញុំ ឈ្មោះ www.btkhmer.com ។ គណិតសាស្ត្រនោះសម្រាប់ និស្សិត ឆ្នាំដំបូង នៅ

មហាវិទ្យាល័យ ។ ខ្ញុំបានដំរាបថា ខ្ញុំស្រឡាញ់គណិតសាស្ត្រ ពុំមែនបានន័យថាខ្ញុំពូកែគណិតសាស្ត្រជាងគេឯងនោះទេ ។ គឺខ្ញុំស្រឡាញ់របៀបត្រិះរិះរកហេតុផល ប្រើពាក្យមានន័យច្បាស់លាស់ មិនអាចឲ្យគេយកទៅបកស្រាយបានច្រើនន័យ ។ ដូចកាលខ្ញុំធ្វើនិក្ខេបបទ លោកសាស្ត្រាចារ្យ Jean LEGRAS គាត់មានប្រសាសន៍ថា ការធ្វើនិក្ខេបបទដើម្បីបានសញ្ញាប័ត្រ នេះជាការធម្មតាទេ តែដែលសំខាន់ គឺគាត់ចង់អប់រំខ្ញុំឲ្យមានគំនិតស្រាវជ្រាវ (esprit de recherche) ។ គឺគំនិតបែបនេះហើយ ដែលធ្វើឲ្យយើងរកឃើញនូវទ្រឹស្តីថ្មីៗ ឬ រកឃើញនូវចម្លើយនៃបញ្ហាថ្មីខ្លះដែលយើងជួបប្រទះ ក្នុងការងារ ឬ ក្នុងការរស់នៅរាល់ថ្ងៃ ។